អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន
# លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុងណូ ហ្វូត ត្រូវបានតែងតាំងជា មេធាវីនាំមុខអន្តរជាតិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុងណូ ហ្វូត (ជាជនជាតិបារាំង) ត្រូវបានតែងតាំងជាមេធាវីនាំមុខអន្តរជាតិសម្រាប់ដើមបណ្តឹងរដ្ឋវេណី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)។

លោកស្រី ស៊ីម៉ុងណូ ហ្វូត ទទួលបានសញ្ញាប័ត្រច្បាប់ពីសាកលវិទ្យាល័យ *ប៉ារីស ២ អាសាស* និងសាកលវិទ្យាល័យ *ប៉ារីស ១០ ណាន់ទែរ*។ លោកស្រីមានបទពិសោធន៍រយៈពេលជាង៣០ឆ្នាំ ជាមេធាវីនៅ *ម៉ុងប៉ែលលីយេ*។ លោកស្រីបានបូជាពេលវេលាក្នុងអំឡុងពេលប្រតិបត្តិច្បាប់របស់លោកស្រី ដើម្បីការពារជនរងគ្រោះនៅក្នុងតុលាការឧក្រិដ្ឋកម្មជាច្រើន ដោយផ្តោតជាពិសេសទៅលើស្ត្រីនិងកុមារ។ លោកស្រី ស៊ីម៉ុងណូ ហ្វូត គឺជាសមាជិកអ្នកបង្កើតសមាគម “អ្នកច្បាប់និងកុមារ” (l’ Avocat et l’ Enfant) និងជាសមាជិកក្រុមមេធាវីផ្តល់សេវាស្ម័គ្រចិត្តដល់ឧក្រិដ្ឋជនដែលជាអនីតិជន។

លោកស្រី ស៊ីម៉ុងណូ ហ្វូត នឹងធ្វើការជាមួយនឹងមេធាវីនាំមុខជាតិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ្រ អង្គ។ សហមេធាវីនាំមុខសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នឹងធានាប្រសិទ្ធិភាពក្នុងការរៀបចំតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលជំនុំជម្រះនិងក្រោយពេលជំនុំជម្រះ។ ការទទួលខុសត្រូវចម្បងរបស់សហមេធាវីនាំមុខរួមមាន ធ្វើជាតំណាងឲ្យផលប្រយោជន៍នៃក្រុមដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗគ្នា តស៊ូមតិជាសាធារណៈ រៀបចំយុទ្ធសាស្ត្រ និងការពារផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីក្នុងតុលាការ។

ព័ត៌មានបន្ថែម សូមទាក់ទង:


| | |
|---|---|
| លោក **ឡាស អូលសិន** | លោក **រាជ សម្បត្តិ** |
| មន្ត្រីទំនាក់ទំនងផ្នែកច្បាប់ | ប្រធានផ្នែកកិច្ចការសាធារណៈ |
| អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) |
| ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣ | ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦ |
| សារអេឡិកត្រូនិក: olsenl@un.org | សារអេឡិកត្រូនិក: reach.sambath@eccc.gov.kh |